ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ...៧៧...ស.សរ

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមការងារដឹកនាំ និងប្រតិបត្តិលើការសិក្សាការចាក់វ៉ាក់សាំងកូវីដ-១៩

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្ដីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្ដីពីវិធានការរដ្ឋបាលដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវនិងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៨៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩
- យោងតាមសំណើរបស់គណៈប្រចាំការនៃគណៈកម្មការជាតិប្រយុទ្ធនឹងជំងឺកូវីដ-១៩

# **សម្រេច**

**ប្រការ១ .-**

បង្កើតក្រុមការងារដឹកនាំ និងប្រតិបត្តិលើការសិក្សាការចាក់វ៉ាក់សាំងកូវីដ-១៩ ដែលមានរចនាសម្ព័ន្ធ និងសមាសភាព ដូចតទៅ៖

I-**ក្រុមប្រឹក្សានាយក** មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- លោកជំទាវវេជ្ជបណ្ឌិត **ឱ វណ្ណឌីន** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | ប្រធាន |
| ២- លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី** | អនុប្រធានក្រុមប្រឹក្សាភិបាលសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA) | អនុប្រធាន |
| ៣- ឯកឧត្តមវេជ្ជបណ្ឌិត **ម៉ឹង វណ្ណារុំ** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ៤- ឯកឧត្តមសាស្ត្រាចារ្យ **សាផុន វឌ្ឍនៈ** | សាកលវិទ្យាធិការនៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | សមាជិក |
| ៥- ឯកឧត្តមសាស្ត្រាចារ្យ **ឈា ឆវណ្ណ** | នាយកវិទ្យាស្ថានជាតិសុខភាពសាធារណៈ | សមាជិក។ |

II-**ក្រុមការងារប្រតិបត្តិលើការសិក្សាការចាក់វ៉ាក់សាំងកូវីដ-១៩** ជាសេនាធិការឱ្យក្រុមប្រឹក្សានាយក ដែលមានសមាសភាព ដូចខាងក្រោម៖

| | | |
|---|---|---|
| ១- លោកបណ្ឌិត **លាង ឬទ្ធា** | ប្រធានកម្មវិធីជាតិប្រយុទ្ធនឹងជំងឺគ្រុនឈាម | ប្រធាន |
| ២- លោកសាស្ត្រាចារ្យរង **អ៊ិរ ម៉** | នាយករងវិទ្យាស្ថានជាតិសុខភាពសាធារណៈ | អនុប្រធាន |
| ៣- លោកបណ្ឌិត **បូរី សុថ្ថាវីរៈ** | ប្រធានការិយាល័យស្រាវជ្រាវ និងផែនការនៃមហាវិទ្យាល័យឱសថសាស្ត្រ | អនុប្រធាន |
| ៤- លោកវេជ្ជបណ្ឌិត **យុខ វុឌ្ឍិកុល** | អនុប្រធានកម្មវិធីជាតិផ្តល់ថ្នាំបង្ការ | សមាជិក |
| ៥- លោកសាស្ត្រាចារ្យ **វ៉ាន់ ម៉ិច** | ប្រធានផ្នែកព្យាបាលជំងឺកូវីដ-១៩ ទី១ មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត | សមាជិក |
| ៦- លោកសាស្ត្រាចារ្យជំនួយ **គីម សុធា** | ប្រធានលេខាធិការដ្ឋាននៃសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល | សមាជិក |
| ៧- លោក **ឌិន សាវុធ** | អនុប្រធានមន្ទីរពិសោធន៍ និងជាប្រធានផ្នែកវីរុសសាស្ត្រនៃវិទ្យាស្ថានសុខភាពសាធារណៈ | សមាជិក |
| ៨- លោកបណ្ឌិត **លឹម ពុទ្ធិជាតិ** | មន្ត្រីជំនួយការស្រាវជ្រាវនៃអគ្គលេខាធិការដ្ឋាននៃគណៈកម្មការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩- លោកវេជ្ជបណ្ឌិត **ស៊ឹម សុខចាន់** | អនុប្រធានសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA) | សមាជិក។ |

**ប្រការ២ ..**

**ក្រុមការងារប្រតិបត្តិលើការសិក្សាការចាក់វ៉ាក់សាំងកូវីដ-១៩ មានផ្នែកគាំទ្រលើការសិក្សា និងវាយតម្លៃលើការចាក់វ៉ាក់សាំងកូវីដ-១៩** ដូចខាងក្រោម៖

- ផ្នែកការងារស្រាវជ្រាវឯកសារ និងសរសេរពិធីសារ ដឹកនាំដោយ លោកបណ្ឌិត **លាង ឬទ្ធា**
- ផ្នែកការងារទទួលបន្ទុកការងារមន្ទីរពិសោធន៍ ដឹកនាំដោយ លោក **ឌិន សាវុធ**
- ផ្នែកការងារទទួលបន្ទុកប្រមូល និងវិភាគទិន្នន័យ ដឹកនាំដោយ លោកបណ្ឌិត **បូរី សុច្ចាធីរៈ**
- ផ្នែកការងារសរសេររបាយការណ៍ ដឹកនាំដោយ លោកសាស្ត្រាចារ្យរង **អ៊ែរ ម៉**

សមាសភាពជាក់ស្តែងរបស់ផ្នែកទាំង ៤ ខាងលើនេះ ត្រូវកំណត់ដោយសេចក្តីសម្រេចដោយឡែករបស់គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស។

**ប្រការ៣ ..**

ក្រុមការងារដឹកនាំ និងប្រតិបត្តិលើការសិក្សាការចាក់វ៉ាក់សាំងកូវីដ-១៩ មានភារកិច្ចដូចតទៅ៖

- ផ្តល់ប្រឹក្សាយោបល់ និងតម្រង់ទិសការងារដល់ការសិក្សាវាយតម្លៃទាក់ទងការចាក់វ៉ាក់សាំងកូវីដ-១៩
- ផ្តល់ប្រឹក្សាយោបល់លើពិធីសារសិក្សា និងវាយតម្លៃ ទាក់ទងនឹងការចាក់វ៉ាក់សាំងកូវីដ-១៩
- ពិនិត្យផ្តល់ប្រឹក្សា និងអនុម័តលើរបាយការណ៍នៃការសិក្សា និងវាយតម្លៃ។
- បង្កើតពិធីសារសិក្សា និងវាយតម្លៃទាក់ទងនឹងការចាក់វ៉ាក់សាំងកូវីដ-១៩ រួមមានរៀបចំវិធីសាស្ត្រ ឧបករណ៍ប្រមូល-វិភាគទិន្នន័យសិក្សា និងវាយតម្លៃទាក់ទងនឹងការចាក់វ៉ាក់សាំងកូវីដ-១៩
- ដឹកនាំ និងសម្របសម្រួលការងារសិក្សា និងវាយតម្លៃទាក់ទងនឹងការចាក់វ៉ាក់សាំងកូវីដ-១៩
- វិភាគ និងរៀបចំរបាយការណ៍សិក្សា និងវាយតម្លៃទាក់ទងនឹងការចាក់វ៉ាក់សាំងកូវីដ-១៩
- អនុវត្តការងារផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សានាយក។

ក្រុមការងារនេះ អាចអញ្ជើញតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ, មន្ត្រីជំនាញ, អ្នកឯកទេស ឬផ្នែកឯកជនចូលរួមប្រជុំ និងប្រឹក្សាយោបល់ទៅតាមតម្រូវការចាំបាច់។

**ប្រការ៤ ..**

រាល់ចំណាយពាក់ព័ន្ធការសិក្សា ការចាក់វ៉ាក់សាំងកូវីដ-១៩ ប្រើកញ្ចប់ថវិកាជាតិ ដោយរៀបចំសំណើដាក់ជូនប្រធានគណៈប្រចាំការនៃ **គ.ប.ក.** ដែលជាឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីពិនិត្យ និងសម្រេច។

**ប្រការ៥ ..**

អនុប្រធាន និងសមាជិកទាំងអស់នៃក្រុមប្រឹក្សានាយក ព្រមទាំងប្រធាន អនុប្រធាន និងសមាជិកនៃក្រុមការងារប្រតិបត្តិលើការសិក្សាការចាក់វ៉ាក់សាំងកូវីដ-១៩ ត្រូវចូលរួមប្រជុំក្រុមការងារដឹកនាំនិងប្រតិបត្តិលើការ

សិក្សាការចាក់វ៉ាក់សាំងកូវីដ-១៩ តាមការអញ្ជើញរបស់ប្រធានក្រុមប្រឹក្សានាយក។ ក្នុងករណី ប្រធានក្រុមប្រឹក្សានាយកអវត្តមាន ឬមានធុរៈ អនុប្រធានក្រុមប្រឹក្សានាយកដែលបានទទួលសិទ្ធិពីប្រធាន អាចកោះប្រជុំ និងដឹកនាំកិច្ចប្រជុំជំនួសបាន។

**ប្រការ៦ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៧ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ព្រមទាំងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៧កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ